MEDIA STATEMENT

UNITED NATIONS HUMAN RIGHTS SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# សេចក្តីថ្លែងការណ៍តាមប្រព័ន្ធផ្សព្វផ្សាយដោយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្ស ប្រចាំប្រទេសកម្ពុជា ស្តីពីការបន្ធូរបន្ថយលក្ខខណ្ឌត្រួតពិនិត្យតាមផ្លូវតុលាការមួយចំនួនលើ លោក កឹម សុខា ដោយតុលាការកម្ពុជា

ទីក្រុងហ្សឺណែវ (១១ វិច្ឆិកា ២០១៩) - អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា អ្នកស្រី រ៉ូណា ស្មីត ស្វាគមន៍ការបន្ធូរបន្ថយលក្ខខណ្ឌត្រួតពិនិត្យតាមផ្លូវតុលាការមួយចំនួនលើ លោក កឹម សុខា ប្រធានគណៈបក្សប្រឆាំងរបស់ប្រទេសកម្ពុជា។ ដីការតុលាការហាមឃាត់ លោក សុខា មិនឲ្យធ្វើសកម្មភាពនយោបាយណាមួយ ឬធ្វើដំណើរទៅក្រៅប្រទេសកម្ពុជា ហើយតម្រូវឲ្យលោកបង្ហាញខ្លួននៅពេលមានការកោះហៅពីគ្រប់អជ្ញាធរមានសមត្ថកិច្ច។ អ្នកស្រី ស្មីត ចេញសេចក្តីថ្លែងការណ៍ដូចខាងក្រោម៖

"ការដោះលែង លោក កឹម សុខា ឲ្យនៅក្រៅឃុំឃាំងក្នុងលំនៅដ្ឋាន ជាការវិវឌ្ឍទៅមុខមួយ ប៉ុន្តែ ខ្ញុំសោកស្តាយ ដែលតុលាការបន្តរឹតត្បិតសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ លោក កឹម សុខា ជាពិសេស សេរីភាពក្នុងការដើរហើរ និងការជួបប្រជុំ។ ខ្ញុំសូមអំពាវនាវជាថ្មីម្តងទៀតឲ្យមានការបិទបញ្ចប់ការស៊ើបសួរឲ្យបានឆាប់រហ័ស ចំពោះករណីលោក សុខា ឬក៏ទម្លាក់ចោលបទចោទប្រកាន់ទាំងឡាយប្រឆាំងនឹងលោក។

ខ្ញុំនៅតែមានកង្វល់ចំពោះជោគវាសនារបស់សកម្មជនគណបក្សសង្គ្រោះជាតិចំនួន ៨៥ រូប ដែលត្រូវបានអាជ្ញាធរចាប់ឃុំខ្លួនក្រោមហេតុផលនយោបាយ។

ខ្ញុំសូមទទូចជាថ្មីម្តងទៀតដល់រដ្ឋាភិបាល និងគណបក្សនយោបាយទាំងអស់ ឲ្យកាត់បន្ថយការរីករាលដាលនៃភាពតានតឹង និងស្វែងរកកិច្ចសន្ទនាក្នុងបរិយាសកាសសន្តិវិធីមួយ ដោយអនុញ្ញាតឲ្យសំឡេងនយោបាយផ្ទុយអាចសម្តែងចេញបាន ព្រមទាំងបញ្ចៀសការរឹតត្បិតតទៅទៀតលើសិទ្ធិសេរីភាពខាងគំនិត ការបញ្ចេញយោបល់ និងការជួបប្រជុំដោយសន្តិវិធី"។

ចប់

***លោកស្រី សាស្ត្រាចារ្យ រ៉ូណា ស្មីត*** *(ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជា អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១៥។*

អ្នករាយការណ៍ពិសេស ពួកគាត់គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឃ្លាំមើល និងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញ  ឯករាជ្យ ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ។ ពួកគាត់បម្រើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។

ពិនិត្យមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីប្រទេសកម្ពុជា និង មើលទំព័រហ្វេសប៊ុករបស់អ្នករាយការណ៍ពិសេស https://www.facebook.com/SpecialRapporteurCambodia/?modal=admin_todo_tour សិទ្ធិមនុស្ស អ.ស.ប ទំព័រប្រទេស៖ ប្រទេសកម្ពុជា

សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖

លោកស្រី អ៊ីស្ធឺរ ឡាំ (Esther Lam) តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩២៨ ៩១ ០៨ ឬ អ៊ីម៉ែល elam@ohchr.org ម៉ាសម៉ូដ ហ្គារហ្គា តាមរយៈទូរស័ព្ទ៖ (+៨៥៥ (0)១២ ៧៩០ ១៧៨ អ៊ីម៉ែល mgarga@ohchr.org)

សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖

លោក ហ្សេរ៉ឺមី ឡូរង់ស៍ (Jeremy Laurence) សិទ្ធិមនុស្ស អ.ស.ប– អង្គភាពប្រព័ន្ធផ្សព្វផ្សាយ តាមរយៈទូរស័ព្ទលេខ៖ (+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីម៉ែល jlaurence@ohchr.org)